**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៨២ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៥ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ

នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប (**វ.ព.ល.**) ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពការងារ អប់រំបណ្តុះបណ្តាល ការរៀន ការបង្រៀន ការស្រាវជ្រាវ កម្មសិក្សា និងនវានុវត្តន៍របស់វិទ្យាស្ថាន។

## ជំពូកទី២
## ភារកិច្ចនិងរចនាសម្ព័ន្ធរបស់ វ.ព.ល.

**មាត្រា២ .-**

**វ.ព.ល.** មានភារកិច្ចដូចខាងក្រោម៖

- រួមចំណែកសម្រេចនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បណ្តុះបណ្តាលធនធានមនុស្សដោយផ្តោតលើបច្ចេកវិទ្យានិងវិទ្យាសាស្ត្រកសិកម្ម
- សិក្សាស្រាវជ្រាវដោយផ្តោតលើបច្ចេកវិទ្យានិងវិទ្យាសាស្ត្រកសិកម្ម
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ ស្រាវជ្រាវ អង្គការនានា និងវិស័យឯកជន ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងអភិវឌ្ឍន៍
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣ .-**

**វ.ព.ល.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- មហាវិទ្យាល័យក្សេត្រសាស្ត្រនិងជីវបច្ចេកវិទ្យា
- មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ ជលផល និងបរិស្ថាន
- មហាវិទ្យាល័យផលិតកម្មសត្វនិងវេជ្ជសាស្ត្រសត្វ
- មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាហារ
- មហាវិទ្យាល័យសេដ្ឋកិច្ចនិងធុរកិច្ចកសិកម្ម
- មហាវិទ្យាល័យបច្ចេកវិទ្យានិងវិស្វកម្មកសិកម្ម
- សាលាបណ្តុះបណ្តាលបច្ចេកទេសនិងភាសាបរទេស (ថ្នាក់ស្មើមហាវិទ្យាល័យ)
- សាលាក្រោយបរិញ្ញាបត្រ (ថ្នាក់ស្មើមហាវិទ្យាល័យ)
- មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មនិងអាហារូបត្ថម្ភ (ថ្នាក់ស្មើមហាវិទ្យាល័យ)។

មហាវិទ្យាល័យនីមួយៗ ត្រូវដឹកនាំដោយព្រឹទ្ធបុរស១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងព្រឹទ្ធបុរសរង មួយចំនួនជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាម លិខិតបទដ្ឋានគតិយុត្តជាធរមាន។

សាលានីមួយៗ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងមាននាយករងមួយ ចំនួនជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាម លិខិតបទដ្ឋានគតិយុត្តជាធរមាន។

មជ្ឈមណ្ឌល ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងមាននាយករងមួយចំនួន ជាជំនួយការ ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្របតាមលិខិត បទដ្ឋានគតិយុត្តជាធរមាន។

**ភ.ភ.ឈ.** អាចស្នើសុំបង្កើតមហាវិទ្យាល័យ សាលា មជ្ឈមណ្ឌល និងអង្គភាពចំណុះផ្សេងទៀតតាមការ ចាំបាច់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ **ភ.ភ.ឈ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពចំណុះផ្សេងទៀតនៃ **ភ.ភ.ឈ.** ត្រូវ កំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

**ភ.ភ.ឈ.** មានសិទ្ធិប្រើត្រានិងរូបសញ្ញាដាច់ដោយឡែក ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួនដែល កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៦ .-**

**ភ.ភ.ឈ.** អាចបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រ ក្រុមប្រឹក្សា និងគណៈកម្មការនានាស្របតាមលិខិតបទដ្ឋានគតិ យុត្តជាធរមាន។

## ជំពូកទី៣
## ភារកិច្ចរបស់មហាវិទ្យាល័យនិងថ្នាក់ប្រហាក់ប្រហែល

**មាត្រា៧ .-**

មហាវិទ្យាល័យក្សេត្រសាស្ត្រនិងជីវបច្ចេកវិទ្យាមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការ និងយុទ្ធសាស្ត្ររបស់ **ភ.ភ.ឈ.**
- អភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាឧត្តមសិក្សាសម្រាប់មហាវិទ្យាល័យក្សេត្រសាស្ត្រនិងជីវបច្ចេកវិទ្យា
- អប់រំបណ្តុះបណ្តាលធនធានមនុស្សតាមជំនាញរបស់មហាវិទ្យាល័យក្សេត្រសាស្ត្រនិងជីវបច្ចេកវិទ្យា

- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណាឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមហាវិទ្យាល័យក្សេត្រសាស្ត្រនិងជីវបច្ចេកវិទ្យា
- គ្រប់គ្រង និងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល**.ប្រគល់ឱ្យ។

**មាត្រា៨ .-**

មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ ជលផល និងបរិស្ថាន មានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **វ.ព.ល**.
- អភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាឧត្តមសិក្សាសម្រាប់មហាវិទ្យាល័យព្រៃឈើ ជលផល និងបរិស្ថាន
- អប់រំបណ្តុះបណ្តាលធនធានមនុស្សតាមជំនាញរបស់មហាវិទ្យាល័យព្រៃឈើ ជលផល និងបរិស្ថាន
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណាឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមហាវិទ្យាល័យព្រៃឈើ ជលផល និងបរិស្ថាន
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល**. ប្រគល់ឱ្យ។

**មាត្រា៩ .-**

មហាវិទ្យាល័យផលិតកម្មសត្វនិងវេជ្ជសាស្ត្រសត្វមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **វ.ព.ល**.
- អភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាឧត្តមសិក្សាសម្រាប់មហាវិទ្យាល័យផលិតកម្មសត្វនិងវេជ្ជសាស្ត្រសត្វ
- អប់រំបណ្តុះបណ្តាលធនធានមនុស្សតាមជំនាញរបស់មហាវិទ្យាល័យផលិតកម្មសត្វនិងវេជ្ជសាស្ត្រសត្វ
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណាឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌

- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមហាវិទ្យាល័យផលិតកម្មសត្វនិងវេជ្ជសាស្ត្រសត្វ
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល.** ប្រគល់ឱ្យ។

**មាត្រា១០ .-**

មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាហារមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **វ.ព.ល.**
- អភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាឧត្តមសិក្សាសម្រាប់មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាហារ
- អប់រំបណ្ដុះបណ្ដាលធនធានមនុស្សតាមជំនាញរបស់មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាហារ
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណា ឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្ដល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាហារ
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល.** ប្រគល់ឱ្យ។

**មាត្រា១១ .-**

មហាវិទ្យាល័យសេដ្ឋកិច្ចនិងធុរកិច្ចកសិកម្មមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **វ.ព.ល.**
- អភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាឧត្តមសិក្សាសម្រាប់មហាវិទ្យាល័យសេដ្ឋកិច្ចនិងធុរកិច្ចកសិកម្ម
- អប់រំបណ្ដុះបណ្ដាលធនធានមនុស្សតាមជំនាញរបស់មហាវិទ្យាល័យសេដ្ឋកិច្ចនិងធុរកិច្ចកសិកម្ម
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណាឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្ដល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមហាវិទ្យាល័យសេដ្ឋកិច្ចនិងធុរកិច្ចកសិកម្ម
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល.** ប្រគល់ឱ្យ។

**មាត្រា១២ .-**

មហាវិទ្យាល័យបច្ចេកវិទ្យានិងវិស្វកម្មកសិកម្មមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ភ.ព.ល.**
- អភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សាឧត្តមសិក្សាសម្រាប់មហាវិទ្យាល័យបច្ចេកវិទ្យានិងវិស្វកម្មកសិកម្ម
- អប់រំបណ្តុះបណ្តាលធនធានមនុស្សតាមជំនាញរបស់មហាវិទ្យាល័យបច្ចេកវិទ្យានិងវិស្វកម្មកសិកម្ម
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណាឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមហាវិទ្យាល័យបច្ចេកវិទ្យានិងវិស្វកម្មកសិកម្ម
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **ភ.ព.ល.** ប្រគល់ឱ្យ។

**មាត្រា១៣ .-**

សាលាបណ្តុះបណ្តាលបន្តនិងភាសាបរទេសមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ភ.ព.ល.**
- សម្របសម្រួលនិងអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងភាសាបរទេស សមស្របតាមតម្រូវការទីផ្សារ
- គ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ស្របតាមគុណវុឌ្ឍិអប់រំបណ្តុះបណ្តាលនិង វិជ្ជាជីវៈ
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេររបាយការណ៍ស្រាវជ្រាវ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍន៍សាលា
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈសាលា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **ភ.ព.ល.** ប្រគល់ឱ្យ។

**មាត្រា១៤ .-**

សាលាក្រោយបរិញ្ញាបត្រមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **ភ.ព.ល.**

- សម្របសម្រួលនិងអភិវឌ្ឍកម្មវិធីសិក្សា សម្រាប់ការអប់រំបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត
- គ្រប់គ្រងការអប់រំបណ្តុះបណ្តាលធនធានមនុស្សតាមកម្មវិធីសិក្សារបស់ខ្លួន
- ដឹកនាំនិស្សិតស្រាវជ្រាវ រៀបចំ និងសរសេរសារណាឬនិក្ខេបបទ
- បង្កើតនិងដឹកនាំគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវឬសៀវភៅតាមជំនាញរបស់ខ្លួន
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍសាលា
- គ្រប់គ្រងនិងវាយតម្លៃនិស្សិត គ្រូ អ្នកស្រាវជ្រាវ និងបុគ្គលិក ព្រមទាំងសម្ភារៈសាលា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល.** ប្រគល់ឱ្យ។

**មាត្រា១៥ .-**

មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មនិងអាហារូបត្ថម្ភមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងអនុវត្តផែនការរបស់ខ្លួន ស្របតាមផែនការនិងយុទ្ធសាស្ត្ររបស់ **វ.ព.ល.**
- បង្កើតនិងគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយសៀវភៅឬអត្ថបទស្រាវជ្រាវ
- រៀបចំនិងសម្របសម្រួលវេទិកាវិទ្យាសាស្ត្រ សម្រាប់ការបង្ហាញលទ្ធផលសិក្សាស្រាវជ្រាវ
- គាំពារការងារសហគ្រិនភាពនិងសហគមន៍ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម បរិស្ថាន និងវប្បធម៌
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងឯកជនព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំស្រាវជ្រាវ និងនវានុវត្តន៍
- ផ្តល់សេវាប្រឹក្សាយោបល់ ការងារបច្ចេកទេស និងស្រាវជ្រាវដល់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងនីតិបុគ្គលផ្សេងៗទៀត
- អភិវឌ្ឍសមត្ថភាពធនធានមនុស្សលើការងារសិក្សាស្រាវជ្រាវ
- សហការជាមួយគ្រឹះស្ថានអប់រំ អង្គភាពរដ្ឋ និងផ្នែកឯកជន ព្រមទាំងដៃគូនានា ដើម្បីជំរុញការងារអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍
- កៀរគរធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍមជ្ឈមណ្ឌលរបស់ខ្លួន
- គ្រប់គ្រងនិងវាយតម្លៃអ្នកស្រាវជ្រាវនិងបុគ្គលិក ព្រមទាំងសម្ភារៈមជ្ឈមណ្ឌល
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូននាយកវិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយក **វ.ព.ល.** ប្រគល់ឱ្យ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនានាចំពោះ **វ.ព.ល.** ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**ជំពូកទី៥**

**អវសានប្បញ្ញត្តិ**

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០២៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

## អង្គការលេខរបស់វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

